**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# របាយការណ៍ប្រចាំឆ្នាំ ២០១៥

# ស្តីពី

# លទ្ធផលនិងសមិទ្ធិផលសំខាន់ៗ

## ពីការអនុវត្តន៍គម្រោងទាំងឡាយរបស់ *អង្គការខ្មែរដើម្បីការអប់រំ*

**ក្នុងភាពជាដៃគូ**

**ជាមួយការិយាល័យអប់រំ យុវជន និងកីឡាស្រុកសំឡូត និងមន្ទីរអប់រំយុវជន និងកីឡា ខេត្ត បាត់ដំបង**

**និង**

**ដោយកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរមូលដ្ឋាន ភូមិ-ឃុំ និងរដ្ឋបាលស្រុក ស្រុកសំឡូត ខេត្តបាត់ដំបង**

## I- ឈ្មោះគម្រោងទី១
## លើកកម្ពស់សិទ្ធិកុមារ និងការអប់រំកុមារតាមជនបទ

## ទិដ្ឋភាពរួម

អង្គការខ្មែរដើម្បីការអប់រំ (KHEN) បានអនុវត្តការងារផ្នែកវិស័យពីរសំខាន់គឺៈ

១/ផ្នែកលើកកម្ពស់សិទ្ធិកុមារនិងកិច្ចការពារកុមារ ២/ផ្នែកអប់រំកុមារតាមជនបទ ដែលគម្រោងទាំងពីនេះ អនុវត្តចំនួន៤ឃុំគឺ: មានឃុំតាតោក ឃុំកំពង់ល្ពៅ ឃុំស៊ុង និងឃុំតាសាញ ដែលមាន ២៤ភូមិ (ភូមិដូនត្រិត ព្រៃរំចេក អូរទន្ទឹម កញ្ចាំង ភូមិស៊ុង၊ ស៊ុង៲ ស្វាយជ្រុំ កំពង់ល្ពៅ អូរដើមចេក អូរជាំលើ អូរជាំក្រោម អូរជាំកណ្តាល ស្ទឹងតូច ភូមិព្រៃធំ ភូមិកណ្តាល អូរក្រូច អូរតាទៀក ពាម តា តាតោក អូរនៃនោង អូរត្រែង វាលរលឹម ភូមិភ្នំរៃ ភូមិពាម) ក្នុងនោះអនុវត្ត ជាមួយសាលាកម្រងចំនួន៥គឺ: (កម្រងអូរតាទៀក អូរជាំ តាសញ កម្រងស៊ុង និង កម្រងអភិវឌ្ឍន៍) ដែលមានសាលា ចំនួន ១៤សាលារដ្ឋគឺ: (សាលាចំការស្ទឹង ស៊ុង၊ ស៊ុង៲ សន្តិភាព ភ្នំរៃ អូរតាទៀក អូរសំរិល អូរនៃនោង ពាមតា អូរជាំ កំពង់ល្ពៅ ស្ទឹងតូច ស្ទឹងតូចក្រោម អក្សរតេ) និង សាលាសហគមន៍ចំនួន១១គឺ (សាលាដូនត្រិត ភ្នំឬស្សី កណ្តាល សុខសាន្ត តាតោក ពាមតា ចម្លងរមាំងអូរដើមចេក អូរជាំក្រោម អូរជាំ អូរខ្ចៅ) ក្នុងស្រុកសំឡូត ខេត្តបាត់ដំបង។

បច្ចុប្បន្នអង្គការខ្មែរដើម្បីការអប់រំ (KHEN) បានទទួលថវិការសំរាប់អនុវត្តនគម្រោងឆ្នាំ២០១៥ នេះ ដោយមានការសហការឧបត្ថម្ភពីម្ចាស់មូលនីធិ EDUCO ពីប្រទេសអេស្បាញ (ដោយមានបដិភាគពីសហគមន៍) និង បន្តគម្រោងដដែលនេះសម្រាប់ឆ្នាំ២០១៦ខាងមុខ។

## លទ្ធផលសំរេចបាន

- **សកម្មភាពទី១: យុទ្ធនាការប្រមូលសិស្សចូលរៀនៈ**
  សហការជាមួយនាយក គ្រូបង្រៀន និងគណកម្មការទ្រទ្រង់សាលា អាជ្ញាធរមូលដ្ឋាននិងសិស្សានុសិស្ស រៀបចំក្បួនដង្ហែយុទ្ធនាការប្រមូលសិស្សចូលរៀនក្នុង១៤សាលារដ្ឋ និង ១១សាលាសហគមន៍ មានអ្នកចូលរួមសរុប ២១៤ នាក់ស្រី១០៣នាក់ ក្នុងនោះបានជម្រុញការលើកទឹកចិត្តមាតាបិតាអោយបញ្ជូនកូនមកចុះឈ្មោះក្នុងមត្តេយ្យសហគមន៍ មត្តេយ្យរដ្ឋ និង សាលាបឋមសិក្សា។

- **សកម្មភាពទី២: ដំណើរការថ្នាក់រៀន និងធ្វើកិច្ចសន្យាគ្រូសហគមន៍ៈ**
  -រៀបចំដំណើរការថ្នាក់រៀនចំនួន១១សាលាសហគមន៍ (មានថ្នាក់មត្តេយ្យសិក្សាសហគមន៍ចំនួន៤សាលា និងបឋមសិក្សាសហគមន៍៧សាលា) សិស្សសរុប ៥៥៤ស្រី ២២២នាក់ បានបន្តនិងចូលរៀន។

-ផ្តល់ការឧបត្ថម្ភប្រាក់ខែគ្រូសហគមន៍១១នាក់(ស្រី៩នាក់) ក្នុងមួយនាក់ថវិកា$៥៥.០០ក្នុង១ខែ និង ឧបត្ថម្ភប្រាក់ខែគ្រូរដ្ឋ៣នាក់ស្រី១នាក់ក្នុងមួយនាក់ទទួលបាន$២០.០០ក្នុង១ខែពេញ១ឆ្នាំសិក្សា ២០១៤-២០១៥។

-ដំណើរការនិងផ្តល់សម្ភារៈតុបតែងថ្នាក់កម្មវិធីសាលាកុមារមេត្រី១ឈុត និងសម្ភារៈឧបទេសក៍សំរាប់ផលិតក្នុងការរៀន និងបង្រៀន១ឈុត (មាន: ក្រដាស់កាតុង ក្រដាស់រាមធំ ក្រដាស់ពណ៌ គូល័រ ហ្វឺត កន្ត្រៃ ការហិបដែក តារាទាំង៩ និងសម្ភារះផ្សេងៗទៀត និង សម្ភារះសម្រាប់ផលិតគាំទ្រដល់ការរៀននិងបង្រៀន) ដល់១៤សាលារដ្ឋ និង១១សាលាសហគមន៍ ក្នុងការរៀបចំនិងតាក់តែងថ្នាក់រៀនដល់សិស្សចូលចិត្ត និងមានការទាក់ទាញដល់ការសិក្សារបស់សិស្ស។

- **សកម្មភាពទី៣: គាំទ្រ និងដំណើការបណ្ណាល័យជ្រុងសម្រាប់សាលារដ្ឋនិងសាលាសហគមន៍៖**
  -ដំណើរការនិងផ្តល់នូវសម្ភារៈបណ្ណាល័យជ្រុងដល់ ២៥សាលារៀន ហើយផ្តល់នៅសៀវភៅរឿង សៀវភៅផាត់ពណ៌ ក្រដាស់កាតុង ក្រដាស់រាមធំ ក្រដាស់ពណ៌ គូល័រ ហ្វឺត កន្ត្រៃ ការ ហិបដែក និងសម្ភារះផ្សេងៗទៀត សម្រាប់សកម្មភាពបណ្ណាល័យសិស្សនិងបណ្ណារក្ស។

  -សម្របសម្រួលជាមួយមន្ត្រីអប់រំជំនាញ បណ្តុះបណ្តាលបណ្ណារ័ក្សស្តីពីៈការគ្រប់គ្រងបណ្ណាល័យ ការរៀបចំគ្រប់គ្រងសៀវភៅ ការផលិតសម្ភារៈនិងការរៀបចំបន្ទប់បណ្ណាល័យ១លើកអ្នកចូលរួមសរុប៤៥នាក់ ស្រី១៨នាក់ និងបានរៀបចំផែនការអនុវត្តបន្តសម្រាប់ឆ្នាំសិក្សា២០១៥-២០១៦។

- **សកម្មភាពទី៤: ការធ្វើផែនទីអង្គការ និងអ្នកពាក់ព័ន្ធជាមួយគម្រោង៖**
  -រៀបចំសិក្ខាសាលាផ្សព្វផ្សាយពីគម្រោងកម្មវិធីបន្តសម្រាប់៣ឆ្នាំបន្ត (២០១៤-២០១៧) នៅសាលប្រជុំសាលាស្រុកសំឡូត១លើកអ្នកចូលរួមសរុប៣៧ស្រី១៩នាក់ ដើម្បីសហការភាពជាដៃគូរ និង បានសិក្សាពីតម្រូវការជាក់លាក់និងផែនការឆ្លើយតបរបស់គម្រោង និងការចូលរួមពីការិយាល័យពាក់ព័ន្ធ និងមូលដ្ឋានគ្រប់លំដាប់ថ្នាក់ ក្នុងសហគមន៍ និងបានរៀបចំសិក្ខាសាលារៀបចំការធ្វើផែនទីអង្គការពាក់ព័ន្ធជាមួយគម្រោង១លើកនៅសាលប្រជុំសាលាស្រុកសំឡូត អ្នកចូលរួមសរុប២៨ស្រី១៧នាក់ ។

- **សកម្មភាពទី៥: បណ្តុះបណ្តាលគណៈកម្មការទ្រទ្រង់សាលា៖**
  -បើកវគ្គបណ្តុះបណ្តាលដល់គណៈកម្មការទ្រទ្រងសាលាស្តីពីៈតួនាទី និងការទទួលខុសត្រូវក្នុងការ ចូលរួមអភិវឌ្ឍន៍សហគមន៍២លើក អ្នកចូលរួមសរុប៦៣នាក់ ស្រី៣៥នាក់ពិការ៧នាក់ ជនជាតិភាគតិច ២នាក់ ស្រី ២នាក់ និងគណៈកម្មការមានសមត្ថភាពចលនាធនធាន សម្រាប់អភិវឌ្ឍសាលារៀន។

  -សហការ បានរៀបចំប្រជុំគណកម្មការទ្រទ្រង់សាលា និងគ្រូបង្រៀនតាមសាលារៀន ធ្វើផែនការណ៍អភិវឌ្ឍន៍សាលាគោលដៅ១៤សាលារដ្ឋនិង១១សាលាសហគមន៍ ប្រចាំឆ្នាំ/១ឆ្នាំម្តង។

-ប្រជុំគណកម្មការទ្រទ្រង់សាលា គាំទ្របច្ចេកទេស និងការគៀរគរសហគមន៍២៥សាលារាងរាល់១ខែម្តង សរុបចំនួន២០លើក អ្នកចូលរួមសរុប៣០៩ស្រី១៤៩នាក់ពិការ១៣នាក់ជនជាតិភាគតិច១៧ស្រី១០នាក់។

-សិក្ខាសាលាឆ្លុះបញ្ចាំងពីសកម្មភាពគណៈកម្មការទ្រទ្រង់សាលា ក្នុងការជួយអភិវឌ្ឍន៍សាលារៀនរយៈពេល១ឆ្នាំសិក្សាទាំង៥កម្រងបាន៣លើក អ្នកចូលរួមសរុប៧៩ស្រី២១នាក់ពិការ១៤នាក់ស្រី០នាក់ ជនជាតិ២ស្រី២នាក់ ដោយបានឆ្លុះបញ្ចាំងពីលទ្ធផល បញ្ហាប្រឈម ចំណុចខ្លាំងនិងខ្សោយ និងរៀបចំផែនការ សកម្មភាពបន្តឆ្លើយតបនិងកែរតម្រូវការអនុវត្តសម្រាប់ឆ្នាំបន្ទាប់។

- **សកម្មភាពទី៦: បណ្តុះបណ្តាលពង្រឹងសមត្ថភាពមាតាបិតាគំរូ:**

-រៀបចំការបណ្តុះបណ្តាលមាតាបិតាល្អ/គំរូស្តីពី: សិទ្ធិកុមារ កិច្ចការពារកុមារ និងផ្តល់គុណតំលៃនៃការសិក្សាសម្រាប់កូនៗ/កុមារ ចំនួន៤លើក ដោយមានអ្នកចូលរួមសរុប១១២ស្រី៧៤នាក់ ពិការ៣នាក់។

-បានប្រជុំមាតាបិតាគំរូ (ជាជនបង្គោល) ចំនួន ៤៤លើក ក្នុងចំនួន២៥ក្រុម ក្នុង ឃុំតាគោក កំពង់ល្ពៅ ឃុំតាសាញ និង ឃុំស៊ុង អ្នកចូលរួមសរុប ៩០២ ស្រី៤០៥នាក់ ពិការ ២០ ស្រី១នាក់ ជនជាតិភាគតិច ១៥ ស្រី៤នាក់ ដោយនិយាយបើកចំហនិងពិភាក្សាពីគុណតម្លៃសិក្សារបស់កូន និងការជួយជ្រុមជ្រែមពីមាតាបិតា ឬអាណាព្យាបាល ដែលដឹកនាំដោយគណៈកម្មការស្ត្រីនិងកុមារថ្នាក់ឃុំ និងភូមិ ចុះតាមដាន និងផ្តល់យោបល់ និងផ្សព្វផ្សាយបន្តជាមួយក្រុមមាតាបិតា និងប្រជាពលរដ្ឋយល់ដឹងនិងកាត់បន្ថយអំពើហិង្សាលើកុមារដែលអាចជះផលអាក្រក់ដល់កុមារ។

-រៀបចំសិក្ខាសាលាឆ្លុះបញ្ចាំងពីសកម្មភាពរបស់ជនបង្គោល (មាតាបិតាគំរូ) ក្នុងការចូលរួមផ្សព្វផ្សាយស្តីពីសិទ្ធិកុមារ កិច្ចការពារកុមារ និងគុណតំលៃនៃការសិក្សា ដល់សហគមន៍បាន១លើក៤៥នាក់ស្រី៣៥នាក់ ដោយបានចែករំលែកដល់គ្នានិងគ្នាពីបទពិសោធន៍ល្អ និងបញ្ហាប្រឈម ដំណោះស្រាយ និងកំណត់ផែនការសកម្មភាពសម្រាប់អនុវត្តបន្ត។

-ប្រជុំប្រឹក្សាយោបល់មាតាបិតា គណកម្មការទ្រទ្រង់សាលា នាយក គ្រូបង្រៀន ផ្សព្វផ្សាយពីគុណតម្លៃនៃការសិក្សា និងការទទួលបានសិទ្ធិចូលរៀន ផងដែរពិភាក្សាពីបញ្ហាប្រឈមនិងហានីភ័យដែលអាចកើតមានចំពោះកុមារ និង កិច្ចការពារកុមារ ដោយបានអនុវត្ត២ខែម្តង សរុប បាន២២ដង នៅតាមសលាគោលដៅ ដោយមអ្នកចូលរួម ៥៨៦នាក់ ស្រី៣៧៥នាក់ មានជនពិការ ២១នាក់ ស្រី៣នាក់ ជនជាតិភាគតិច ២៧នាក់ស្រី២១នាក់ ដែលបានផ្តល់នូវការយល់ដឹងនិងជជែកគ្នាត្រង់ពីសវនកម្មសង្គមនិង តម្រូវការរបស់កុមារ និងកាតព្វកិច្ចរបស់មនុស្សធំ និងរដ្ឋភាគីហត្ថលេខីនៃអនុសញ្ញាស្តីពីសិទ្ធិកុមារអន្តរជាតិ។

- **សកម្មភាពទី៧: វគ្គបំប៉ន គ្រូបង្រៀនតាមសាលាបឋមសិក្សា និងគ្រូតាមសលាសហគមន៍ស្តីពី៖**
  -សហការជាមួយការិយាល័យអប់រំស្រុក បានបើកវគ្គបណ្តុះបណ្តាលគ្រូបង្រៀន ស្តីពី **គោលវិធីសិស្សមជ្ឈមណ្ឌល និងកម្មវិធីសាលាកុមារមេត្រី** ចំនួន៤លើកនៅសាលប្រជុំការិយាល័យ អប់រំស្រុកសំឡូត អ្នកចូលរួមសរុប ១៥៩នាក់ ស្រី៧៥នាក់ជនពិការ៧នាក់ ស្រី១នាក់ ជនជាតិភាគតិច១០ ស្រី៦នាក់។

  -គាំទ្រការប្រជុំបច្ចេកទេសគ្រូសាលារបឋមសិក្សា និង គ្រូសហគមន៍ មកពី ៥កម្រងសាលារៀនគោលដៅ មានៈ កម្រងអូរតាទៀកកម្រងអូរជាំ ស៊ុង កម្រងតាសាញ និង កម្រងអភិវឌ្ឍន៍សំឡូត ចំនួន២០ដង អ្នកចូលរួម សរុប៣៤៧ ស្រី២០២ជនពិការ ១៤ស្រី២ ដោយបានពង្រឹងពីការត្រួតពិនិត្យនិងវាយតម្លៃ និងបានរៀបចំកិច្ចតែងការបង្រៀនសិស្ស ការអនុវត្តសាកល្បង និង បង្ហាញពីបច្ចេកទេសបង្រៀន ចែករំលែកដល់គ្រូបង្រៀនថ្មីៗ និងគ្រូសហគមន៍ និងបានរៀបចំផែនការបង្រៀនសិស្ស តាមគោលការណ៍ណែនាំរបស់ក្រសួងអប់រំ យុវជននិងកីឡា។

  -ការចុះផ្តល់ការគាំទ្របច្ចេកទេសនិងគាំទ្រតម្រង់ទិស ពីមន្ត្រីជំនាញការិយាល័យអប់រំស្រុកទៅតាមសាលាគោលដៅ ចំនួន១០លើក មានសាលារៀនៈ បឋមសិក្សាស្ទឹងតូច សាលាអូរជាំ សាលាអូរតាទៀក សាលាអូរជាំក្រោម និង សាលាភូមិកណ្តាល សាលាកំពង់ល្ពៅ សាលាមត្តេយ្យតាតោក និង អូរសំរិល។

- **សកម្មភាពទី៨: បង្កើនទំនាក់ទំនងជាមួយបណ្តាញការងារ៖**
  -បង្កើនទំនាក់ទំនងជាមួយបណ្តាញការងារឃុំ និងភូមិដើម្បីធ្វើចលនារកធនធានចូលរួមក្នុងការសាងសង់សាលា សួន បង្គន់អនាម័យតាមសាលាបឋមសិក្សា និងសាលាសហគមន៍ ចំនួន២៥សាលាគោលដៅ ក្នុង ឃុំតាតោក កំពង់ល្ពៅ ស៊ុង និងតាសាញ ។

- **សកម្មភាពទី៩: ពង្រឹងសមត្ថភាពប្រធានក្រុមក្លឹបកុមារ ក្រុមប្រឹក្សាកុមារ និងសមាជិកក្រុម ៖**
  -បានបើកវគ្គបណ្តុះបណ្តាល ពង្រឹងសមត្ថភាពដល់ប្រធានក្រុមក្លឹបកុមារទាំង៥កម្រង កម្រងអូរជាំ កម្រងអូរតាទៀក កម្រងស៊ុងតាសាញ និង កម្រងអភិវឌ្ឍន៍សំឡូត ៣លើក មានកុមារអ្នកចូលរួម សរុប ៧៤ ស្រី៥៤នាក់ កុមារពិការ១នាក់ ដោយបានបញ្ជ្រាបពីការយល់ដឹងពីសិទ្ធិនិងទំនួលខុសត្រូវរបស់កុមារ និងមនុស្សធំ និងរដ្ឋ និងប្រធានបទបំណិនជីវិតងាយៗដូចជា សុខភាពអនាម័យ កម្មវិធីដង្កូវព្រូន និង កិច្ចការពារខ្លួន ព្រមទាំងបានអនុវត្តវិធីសាស្រ្តផ្សព្វផ្សាយបន្ត អនុវត្តផ្ទាល់ តាមក្រុមពិភក្សា និងរៀបចំផែនការប្រជុំប្រចាំខែជាមួយសមាជិកក្លឹបឬក្រុមប្រឹក្សាកុមារបន្ត ដោយមានការគាំទ្រពីអ្នកស្ម័គ្រចិត្តគម្រោង។

  -សម្របសម្រួលការប្រជុំក្លិបកុមារតាមសាលាគោលដៅ ប្រធានបទស្តីពី: សិទ្ធិកុមារ និង កិច្ចការពារក្នុង២៥ភូមិ បាន១៣៣លើក អ្នកចូលរួមសរុប ៥៣៤៨ ស្រី២៧៣៩នាក់ កុមារពិការ៦៣ ស្រី២៥នាក់ ជនជាតិភាគតិច ១៩៧ ស្រី១២៧នាក់។

- បានរៀបចំសិក្ខាសាលាឆ្លុះបញ្ចាំងពីសកម្មភាពក្រុមក្លិបកុមារស្តីពីៈ លទ្ធផល បញ្ហាប្រឈម ចំណុចល្អ និងចំណុចខ្សោយ ពីការអនុវត្តការផ្សព្វផ្សាយសិទ្ធិកុមារ កិច្ចការពារកុមារ និងការចែករំលែកពីបទពិសោធន៍ល្អពីគ្នាទៅវិញទៅមក បាន៣លើក កុមារប្រធានក្លិបបានចូលរួមសរុប១២៦ ស្រី៧៧នាក់ ពិការ៦ស្រី១នាក់ ជនជាតិភាគតិច ៥នាក់ស្រី៣នាក់ ដោយរំលឹកនិងស្វែងរកវិធិសាស្រ្តល្អ និងផែនការអនុវត្តបន្ត។

-បានរៀបចំទិវាកុមារអន្តរជាតិខួបលើកទី៦៦ តាមសាលាគោលដៅទាំង២៥សាលារៀននិងសាលាសហគមន៍ ក្នុងកម្រងស៊ុង តាសាញ កម្រងអូរតាទៀក និង កម្រងអូរជាំ ដោយមានអ្នកចូលរួម សរុប ២១៥៦ស្រី ១១៣០នាក់ពិការ ២៦ស្រី៨នាក់ ជនជាតិ១០៦ស្រី ៧៦នាក់ ។

-បានគាំទ្រដល់ការប្រជុំគណកម្មការគកសកស្រុក៥លើក នៅសាលប្រជុំសាលាស្រុកសំឡូត ដោយមានឃុំគោលដៅចូលរួមគឺ មានឃុំតាតោក ស៊ុង តាសាញ និងឃុំកំពង់ល្ពៅ ដោយបានលើកឡើងពីរាយការណ៍ករណីកុមារនិងស្រ្តីមានបញ្ហា និងរកដំណោះស្រាយរួមគ្នា និងចលនាធនធានជួយគ្នា ទាំងរដ្ឋនិងដៃគូ ដូចជាស្រ្តីមានបញ្ហាប្រសូត្របុត្រ និងការចេញសំបុត្រកំណើតនិងលិខិតបញ្ជាក់កំណើតកូន ការគាំទ្រដល់មត្តេយ្យសហគមន៍ ជាពិសេសស្រុកបានឯកភាពជាមួយ ឃុំពីរទទួលផ្តល់ថវិកាគាំទ្រគ្រូមត្តេយ្យសហគមន៍ចំនួន៤កន្លែង និងមានការផ្សព្វផ្សាយពីបច្ចុប្បន្នភាព ពីក្រុមប្រឹក្សាស្រុក កំណែរទម្រង់កិច្ចការងាររដ្ឋបាលស្រុក និងពត៌មានទាន់ហេតុការករណីមានការរំលោភបំពានឬសង្ស័យកើតមានឡើង ជាពិសេភូមិឃុំមានសុវត្ថិភាព។

-ជួយគាំទ្រការប្រជុំប្រចាំខែ គ.ក.ន.ក ថ្នាក់ឃុំ ចំនួន៤ឃុំ មានតាតោកកំពង់ល្ពៅតាសាញ់ និង ស៊ុង គិតជាលើកចំនួន១៨លើក អ្នកចូលរួមសរុប ៣៨០នាក់ ស្រី២២៥នាក់ជនពិការ២៤នាក់ ស្រី២នាក់ ដោយបានផ្តោតលើបញ្ហាសិទ្ធិកុមារ និងរបាយការណ៍ពីកុមារនិងស្រ្តី ដែលមានក្នុងសហគមន៍ និង ការដោះស្រាយដូចជាករណីអំពើហិង្សាលើកុមារនិងស្រ្តី ស្រ្តីមាផ្ទៃពោះ កិច្ចការពារហានិភ័យ ជាដើម និង ការចលនាធនធាន និង ការគ្រប់គ្រងនិងចាត់ចែងមត្តេយ្យសិក្សាសហគមន៍ និងបដិភាគពីក្រុមប្រឹក្សាចូលរួម។

-បានគាំទ្រកម្មវិធីសមាហរណកម្មឃុំ ថ្នាក់ស្រុក ១លើក អ្នកចូលរួមសរុប ៦៧ ស្រី ២៤ នាក់ ដោយបានសហការផ្សព្វផ្សាយនិងចាប់យកគម្រោងវិនិយោគឃុំអាទិភាពតាមវិស័យ ដែលមានក្នុងគម្រោង និងបានចុះកិច្ចព្រមព្រៀងសហការ និងធនធានរួមគ្នាបដិភាគក្នុងសកម្មភាពមួយចំនួនតាមកិច្ចសន្យាបណ្តោះអាសន្នសម្រាប់គម្រោងឆ្នាំ២០១៦។

- **សកម្មភាពទី១០: វេទិការសាធារណស្តីពីៈសិទ្ធិកុមារ និងដំណោះស្រាយបញ្ហាកុមារ**
  -បានសហការជាមួយឃុំនិងការិយាល័យអប់រំស្រុក រៀបចំវេទិការសាធារណៈស្តីពី លើកកម្ពស់ការយល់ដឹងពីសិទ្ធិកុមារ កិច្ចការពារកុមារ និងការតស៊ូមតិ ពីការគោរពសិទ្ធិកុមារ បានចំនួន៤លើក (ក្នុងឃុំតាតោក ឃុំកំពង់ល្ពៅ ឃុំតាសាញ និងឃុំស៊ុង) អ្នកចូលរួមសរុប៤៥១នាក់ ស្រី១៩៧នាក់ជនពិការ៣១នាក់ ដោយមានវាគ្មិនចូលរួមបកស្រាយសំណួររបស់ប្រជាពលរដ្ឋនិងកុមារពីបញ្ហាទាក់ទិននិងការអនុវត្តកាតព្វ

ឆ្លើយតបចំពោះ ការជម្រុញការសិក្សារបស់កុមារគ្រប់គ្នា កង្វះគ្រូបង្រៀន និង បញ្ហាម៉ោងសិក្សាមិនគ្រប់ កែលម្អជាសាលាកុមារមេត្រី ការប្រើអំពើហិង្សាលើកុមារ និងពលកម្មកុមារ និង ស្វែងរកថវិកាវិភាជពីឃុំ ឬស្រុកក្នុងការជួយដល់វិស័យអប់រំ និងសុខមាលភាពសង្គម ជាពិសេសមត្តេយ្យសិក្សាសហគមន៍ និង សលាបឋមសិក្សាសហគមន៍។ ក្នុងនោះផងដែរគម្រោងបានសហរៀបចំ៖គាំទ្រកម្មវិធីវេទិការសាធារណៈ និងពិគ្រោះរបស់ក្រុមប្រឹក្សាស្រុក សំឡូតចំនួន២លើកនៅក្នុងឃុំស៊ុង១លើក និង ក្នុងឃុំកំពង់ល្ពៅ១លើកអ្នកចូលរួមសរុប២៨៨ ស្រី៦៨នាក់ ជនពិការ៣៥ស្រី៥នាក់ ក្នុងប្រធានបទពីការចូលរួមពីសហគមន៍ពីបញ្ហាសិទ្ធិដីធ្លី និងការសាងសងផ្លូវ និងការមានប័ណ្ណសំគាល់កម្មសិទ្ធិ និងមានការចូលរួមបកស្រាយដោយក្រុមប្រឹក្សាស្រុក និងរកដំណោះស្រាយ ជូនដល់ប្រជាជន។

- **សកម្មភាពទី១១: គាំទ្រកម្មវិធីបង្រៀនអក្ខរកម្ម(គម្រោងសាកល្បង)៖**
  -គាំទ្រកម្មវិធីបង្រៀនអក្ខរកម្មចំនួន២ភូមិ (ដូនត្រិត ចំការស្ទឹង) សិស្សសរុប២៨ស្រី២៥នាក់ជនពិការ១នាក់ ដោយមានកិច្ចសហការជាមួយកម្មវិធីអប់រំក្រៅប្រព័ន្ធរបស់ការិយាល័យអប់រំ យុវជននិងកីឡាស្រុក ដោយគម្រោងផ្តល់ការគាំទ្រនិងបើកវគ្គបំប៉នបច្ចេកទេស និង ផ្សព្វផ្សាយជាមួយជំនាញ សម្រាប់គ្រូអក្ខរកម្មទាំងអស់ក្នុងស្រុកសំឡូត ដោយឡែកសម្ភារៈនិងប្រាក់ខែគ្រូទទួលបន្ទុកទាំងស្រុងដោយការិយាល័យអប់រំយុវជននិងកីឡាស្រុក ជាលទ្ធផលបានបើកវគ្គពង្រឹងសមត្ថភាពគ្រូអក្ខរកម្ម១លើកអ្នកចូលរួមសរុប៣៣នាក់ ស្រី៨នាក់ ជនពិការ៨ស្រី១នាក់។

- **សកម្មភាព១២: គាំទ្រការបញ្ជូនកុមារងាយរងគ្រោះថ្នាក់ដល់អាយុជីវិតរកសេវាព្យាបាលនិងសង្គ្រោះ**
  -បានគាំទ្រការបញ្ជូនកុមារមានបញ្ហាបន្ទាន់ និងគ្រោះថ្នាក់ដល់អាយុជីវិត(មានជម្ងឺធ្ងន់ធ្ងរ) និងគ្រោះថ្នាក់ភ្លាមៗ ទៅមន្ទីរពេទ្យបាត់ដំបងនិងសៀមរាប ចំនួនសរុបកុមារ ១៥នាក់ ស្រី៧នាក់/១៥គ្រួសារដោយមានកិច្ចសហការពីមូលដ្ឋាន និងមណ្ឌលសុខភាពឬបុស្តិ៍សុខភាពភូមិបញ្ជូនសមស្របនិតទាន់ពេល។

  -បានគាំទ្រគ្រួសារកុមារដាច់ស្បៀង ចំនួន២គ្រួសារនៅភូមិកណ្តាល ភូមិភ្នំរៃ (មានអង្ករ៥០គីឡូ ត្រីខ២យួ ទឹកត្រី ១យួ ទឹកស៊ីអ៊ីវ១យួ ដោយមានបញ្ហាកុមារទទួលរងភ្លើងឆេះផ្ទះ និង ជនជាតិភាគតិចដែលកំពុងដាច់ស្បៀងនិងមិនមានអាហារផ្តល់ដល់កូនៗ និង គម្រោងបានផ្តល់ពត៌មាន និងបានស្វែងរកកិច្ចអន្តរាគមន៍ពីមូលដ្ឋានភូមិ ឃុំ និងស្រុក ដើម្បីជួយបន្ត។

- **សកម្មភាពទី១៣:ការកែលម្អ និងជួសជុលសាលារដ្ឋចំនួន១៤អោយក្លាយជាសាលាកុមារមេត្រី ៖**

- សហការជាមួយនាយកសាលា គណកម្មការទ្រទ្រង់សាលា អាជ្ញាធរ និង សហគមន៍ បានសាងសង់សាលាបឋមសិក្សាសហគមន៍តាមតំបន់ជួបការលំបាកចំនួន៩សាលាថ្មីធ្វើពីឈើ បែបសហគមន៍ ដែលមាន ១៥បន្ទប់ (ក្នុង១បន្ទប់ ប្រវែង ៦ម x ៨ម ) មានរាយនាមខាងក្រោមៈ

  ១-សាលាដូនត្រិត៖ សាងសង់សាលាមួយខ្នង បីបន្ទប់(១បន្ទប់៦មx៨ម=២៤ម)សំរេច១០០%
  ២-សាលាភ្នំឬស្សី៖ សាងសង់សាលាមួយខ្នង មួយបន្ទប់(១បន្ទប់៦មx៨ម)សំរេច១០០%

៣-សាលាភូមិកណ្តាល៖ សាងសង់សាលាមួយខ្នង ពីរបន្ទប់(១បន្ទប់៦មx៨ម)សំរេច៩៥%
៤-សាលាអូរជាំក្រោម៖ សាងសង់សាលាមួយខ្នង មួយបន្ទប់(១បន្ទប់៦មx១០ម)សំរេច១០០%
៥-សាលាអូរខ្ចៅ៖ សាងសង់សាលាមួយខ្នង ពីរបន្ទប់(១បន្ទប់៦មx៨ម=១៦ម)សំរេច៩៥%
៦-សាលាសុខ សាន្ត៖ សាងសង់សាលាមួយខ្នង មួយបន្ទប់(១បន្ទប់៦មx៨ម)សំរេច១០០%
៧-សាលាមត្តេយ្យពាមតា៖ សាងសង់សាលាមួយខ្នង មួយបន្ទប់(១បន្ទប់៦មx៨ម)សំរេច១០០%

- សហការជាមួយនាយកសាលា គណកម្មការទ្រទ្រង់សាលា អាជ្ញាធរមូលដ្ឋាន និង សហគមន៍ជួសជុលតយ៉ាបជម្រកម្លប់សម្រាប់សិស្ស តាមមុខសាលាសហគមន៍ ចំនួន៧សាលារៀន ដែលមាន ៨ បន្ទប់ (ក្នុង១បន្ទប់ បាន ត-យ៉ាបមុខជ្រកកំដៅ ប្រវែង ២.៥ម x ៨ម ) មានរាយនាមខាងក្រោម:

| | | |
|---|---|---|
| ១-សាលាសុខ សាន្ត៖ | (ក្នុង១បន្ទប់តយ៉ាបប្រវែង២.៥មx៨ម) | សំរេច១០០% |
| ២-សាលាមត្តេយ្យពាម តា៖ | (ក្នុង១បន្ទប់តយ៉ាបប្រវែង២.៥មx៨ម) | សំរេច១០០% |
| ៣-សាលាអូរជាំក្រោម៖ | (ក្នុង១បន្ទប់តយ៉ាបប្រវែង២.៥មx៨ម) | សំរេច១០០% |
| ៤-សាលាដូនត្រិត៖ | (ក្នុង១បន្ទប់តយ៉ាបប្រវែង៣មx៨ម=២៤ម) | សំរេច១០០% |
| ៥-សាលាភ្នំឬស្សី៖ | (ក្នុង១បន្ទប់តយ៉ាបប្រវែង២.៥មx៨ម) | សំរេច១០០% |
| ៦-សាលាអូរដើមចេក៖ | (ក្នុង១បន្ទប់តយ៉ាបប្រវែង២.៥មx៨ម) | សំរេច១០០% |
| ៧-សាលាចម្លងរមាំង៖ | (ក្នុង១បន្ទប់តយ៉ាបប្រវែង២.៥មx៨ម) | សំរេច១០០% |

- សាងសង់បង្គន់អនាម័យស្រី ចំនួន១១តាមសាលាសហគមន៍ក្នុងឃុំកំពង់ល្ពៅនិងឃុំតាសាញ និង ឃុំតាតោក មានចំនួន ១៥ បន្ទប់ (ក្នុង១ បន្ទប់ប្រវែង ១.៥ម x ២.៥ម ) និងដាក់ទោងសិស្សលេងទ-ទឹក លូដុតសំរាម កន្លែងលាងដៃ ទីធ្លាសាលាចាក់សាបផ្លូវចូលសាលា ដាក់លួសសំណាញ់របងសលា ដាក់ពាងធំ និង រៀបចំដាំសួនសម្រាប់កុមារលេង។

| | |
|---|---|
| ១-សាលាដូនត្រិត៖ | បង្គន់២បន្ទប់(ក្នុង១បន្ទប់១.៥មx២.៥ម)ដាក់ទោង១ ទទឹក១ លូដុតសំរាម១ ដាក់ពាងធំ២ កន្លែងលាងដៃ សួនសម្រាប់កុមារលេងលទ្ធផលសំរេច១០០% |
| ២-សាលាភ្នំឬស្សី៖ | បង្គន់២បន្ទប់(ក្នុង១បន្ទប់១.៥មx២.៥ម)ដាក់ទោង១ ទទឹក១ លូដុតសំរាម១ ដាក់ពាងធំ២ កន្លែងលាងដៃ សួនសម្រាប់កុមារលេងលទ្ធផលសំរេច១០០% |
| ៣-សាលាភូមិកណ្តាល៖ | បង្គន់១បន្ទប់(ក្នុង១បន្ទប់១.៥មx២.៥ម)ដាក់ទោង១ ទទឹក១ លូដុតសំរាម១ ដាក់ពាងធំ២ កន្លែងលាងដៃ ទីធ្លាសម្រាប់កុមារលេងលទ្ធផលសំរេច១០០% |
| ៤-សាលាអូរជាំក្រោម៖ | បង្គន់២បន្ទប់(ក្នុង១បន្ទប់១.៥មx២.៥ម)ដាក់ទោង១ ទទឹក១ លូដុតសំរាម១ ដាក់ពាងធំ២ កន្លែងលាងដៃសួនសម្រាប់កុមារលេង លទ្ធផលសំរេច១០០% |
| ៥-សាលាខ្ចៅ៖ | បង្គន់២បន្ទប់(ក្នុង១បន្ទប់១.៥មx២.៥ម)ដាក់ទោង១ ទទឹក១ លូដុតសំរាម១ ដាក់ពាងធំ២ កន្លែងលាងដៃ ទីធ្លាសម្រាប់កុមារលេងលទ្ធផលសំរេច១០០% |
| ៦-មត្តេយ្យសាលាអូរជាំ៖ | បង្គន់១បន្ទប់(ក្នុង១បន្ទប់១.៥មx២.៥ម)ដាក់ទោង១ ទទឹក១ លូដុតសំរាម១ ដាក់ពាងធំ២ កន្លែងលាងដៃ សួនសម្រាប់កុមារលេងលទ្ធផលសំរេច១០០% |

៧-សាលាអូរដើមចេក៖ បង្គន់១បន្ទប់(ក្នុង១បន្ទប់១.៥មx២.៥ម)ដាក់ទោង១ ទទឹក១ លូដុតសំរាម១ ដាក់ពាងធំ២ កន្លែងលាងដៃ សួនសម្រាប់កុមារលេងលទ្ធផលសំរេច១០០%

៨-សាលាចម្លងរមាំង៖ បង្គន់១បន្ទប់(ក្នុង១បន្ទប់១.៥មx២.៥ម)ដាក់ទោង១ ទទឹក១ លូដុតសំរាម១ ដាក់ពាងធំ២ កន្លែងលាងដៃ សួនសម្រាប់កុមារលេងលទ្ធផលសំរេច១០០%

៩-មតេយ្យតាគោក៖ បង្គន់១បន្ទប់(ក្នុង១បន្ទប់១.៥មx២.៥ម)ដាក់ទោង១ ទទឹក១ លូដុតសំរាម១ ដាក់ពាងធំ២ កន្លែងលាងដៃ ដាក់លួសសំណាញ់ព័ទ្ធជុំវិញសាលា សួនសម្រាប់កុមារលេងលទ្ធផលសំរេចបាន១០០%

១០-សាលាសុខសាន្ត៖ បង្គន់១បន្ទប់(ក្នុង១បន្ទប់១.៥មx២.៥ម)ដាក់ទោង១ ទទឹក១ លូដុតសំរាម១ ដាក់ពាងធំ២ កន្លែងលាងដៃ សួនសម្រាប់កុមារលេងលទ្ធផលសំរេច១០០%

១១-មត្តេយ្យពាមតា៖ បង្គន់១បន្ទប់(ក្នុង១បន្ទប់១.៥មx២.៥ម)ដាក់ទោង១ ទទឹក១ លូដុតសំរាម១ ចាក់សាបផ្លូវចូលសាលា ជួសជុលក្លោងទ្វារ កន្លែងលាងដៃ សួនសម្រាប់កុមារលេងលទ្ធផលសំរេចបាន១០០%

- សាងសង់បន្ថែមបង្គន់អនាម័យស្រី ១១នៅសាលារដ្ឋ(សាលាថ្មស្រាប់) ក្នុងឃុំកំពង់ល្ពៅ និងឃុំតាសាញ និង ឃុំតាគោកចំនួន១៥បន្ទប់ (បន្ទប់១.៥មx២.៥ម) ដាក់ទោង លូដុតសំរាម សួនច្បា និងទីធ្លាសាលាៈ

-សាលាពាមតា៖ បង្គន់ស្រី១បន្ទប់(ក្នុង១បន្ទប់១.៥មx២.៥ម)លទ្ធផលសំរេច១០០%

-សាលាអូរនទោង៖ បង្គន់ស្រី១បន្ទប់(ក្នុង១បន្ទប់១.៥មx២.៥ម)ដាក់ទោង១ លូដុតសំរាម សួនច្បា និងទីធ្លាសម្រាប់កុមារលេងលទ្ធផលសំរេចបាន១០០%

-សាលាអូរតាទៀក៖ បង្គន់ស្រី១បន្ទប់ (ក្នុង១បន្ទប់១.៥មx២.៥ម)ដាក់ទោង១លូដុតសំរាម ពាងធំ២ ក្លោងទ្វារ សួនច្បា និងទីធ្លាសម្រាប់កុមារលេងលទ្ធផល ទ្វាររបង សំរេចបាន១០០%

-សាលាអូរសំរិល៖ បង្គន់១បន្ទប់ (ក្នុង១បន្ទប់១.៥មx២.៥ម)ដាក់ទោង១ លូដុតសំរាម១ ពាងធំ២ សួនច្បានិងទីធ្លាសម្រាប់កុមារលេងលទ្ធផលសំរេច បាន១០០%

-សាលាភ្នំរៃ៖ បង្គន់១បន្ទប់ (ក្នុង១បន្ទប់១.៥មx២.៥ម)ដាក់ទោង១ លូដុតសំរាម១ សួនច្បា និងទីធ្លាសម្រាប់កុមារលេងលទ្ធផលសំរេចបាន១០០%

-សាលាសុខសាន្ត៖ បង្គន់១បន្ទប់(ក្នុង១បន្ទប់១.៥មx២.៥ម)លទ្ធផលសំរេចបាន១០០%

-សាលាកំពង់ល្ពៅ៖ បង្គន់២បន្ទប់(ក្នុង១បន្ទប់១.៥មx២.៥ម)ដាក់ទោង១ លូដុតសំរាម១ ពាងធំ២ សួនច្បា ជួសជុលបង្អួច និងទីធ្លាសម្រាប់កុមារលេងលទ្ធផលសំរេច១០០%

-សាលាស្ទឹងតូច៖ បង្គន់២បន្ទប់(ក្នុង១បន្ទប់១.៥មx២.៥ម)ដាក់ទោង១ លូដុតសំរាម១ ពាងធំ២ សួនច្បា និងទីធ្លាសម្រាប់កុមារលេងលទ្ធផលសំរេច

បាន១០០%

| | |
|---|---|
| -សាលាព្រៃធំ៖ | បង្គន់២បន្ទប់(ក្នុង១បន្ទប់១.៥មx២.៥ម)លទ្ធផលសំរេចបាន១០០%។ |
| -សាលាអក្សតេះ | បង្គន់២បន្ទប់(ក្នុង១បន្ទប់១.៥មx២.៥ម)ដាក់ទោង១ លូដុតសំរាម១ ពាងធំ២ សួនច្បា និងទីធ្លាសម្រាប់កុមារលេងលទ្ធផលសំរេចបាន១០០% |
| -សាលាអូរជាំ៖ | បង្គន់១បន្ទប់(ក្នុង១បន្ទប់១.៥មx២.៥ម) លទ្ធផលសំរេចបាន១០០% |
| -សាលាស្ទឹងតូចក្រោម៖ | ដាក់ទោង១ លូដុតសំរាម ពាងធំ២ សួនច្បានិងទីធ្លាសម្រាប់កុមារលេងលទ្ធផលសំរេចបាន១០០% |

## II- ឈ្មោះគម្រោងទី២

## ឆានាបាទការអនុវត្តការអប់រំការបញ្ចូលគ្នាសម្រាប់កុមារពិការ

| | |
|---|---|
| រយៈពេលគម្រោង: | ២ឆ្នាំ (ចាប់ពីខែមករា ២០១៥ ដល់ ធ្នូ ២០១៦) |
| ម្ចាស់មូលនីធិ: | ជំនួយរបស់រដ្ឋាភិបាលអូស្ត្រាលីតាមអង្គការយូនីសេហ្វ(Australian Aid through Unicef |
| អនុវត្តគម្រោងដោយ: | អង្គការខ្មែរដើម្បីការអប់រំ (KHEN) *(ដោយមានបដិភាគពីសហគមន៍)* |
| តំបន់គោលដៅ: | សាលាបឋមសិក្សា ១០សាលា (សាលាបឋមសិក្សារដ្ឋ ៦ និងសាលាសហគមន៍ ៤) |

## **ទិដ្ឋភាពរួម**

គម្រោងនេះបានអនុវត្តន៍ចំនួន២ឃុំ មានឃុំតាគោកកំពង់ល្ពៅ ដែលមាន១០ភូមិ(ស្វាយជ្រុំ កំពង់ល្ពៅ អូរដើមចេក ភូមិអូរជាំក្រោម ភូមិស្ទឹងតូចក្រោម ភូមិអូរក្រូច ភូមិអូរតាទៀក ភូមិអូរត្រែង ភូមិវាលរលឹម ភូមិភ្នំរ៉ៃ) ក្នុងនោះអនុវត្តន៍ជាមួយសាលាកម្រងចំនួន២គឺ: កម្រងអូរតាទៀក និងកម្រងអូរជាំ ដែលមានសាលា ចំនួន១០សាលារដ្ឋ គឺៈសាលាភ្នំរ៉ៃ សាលាអូរតាទៀក សាលាអូរសំរិល សាលាអូរននោង សាលាពាមតា សាលាអូរជាំ សាលាកំពង់ល្ពៅ សាលាស្ទឹងតូចក្រោម សាលាភូមិកណ្តាល សាលាអូរជាំក្រោម)។ បច្ចុប្បន្ន **អង្គការខ្មែរដើម្បីការអប់រំ** (KHEN) បានទទួលថវិការសំរាប់អនុវត្តន៍គម្រោង ឆ្នាំ២០១៥ នេះ ដោយមាន ការឧបត្ថម្ភមូលនីធិពីប្រទេសអូស្ត្រាលី តាមរយៈម្ចាស់មូលនីធិ UNICEF កម្ពុជា អនុវត្តគម្រោងអប់បញ្ចូលគ្នា ក្នុងស្រុកសំឡូត ខេត្តបាត់ដំបង។

## **លទ្ធផលសំរេចបាន**

- **កុមារពិការបានចូលរៀនក្នុងកម្រងទាំង២ និងបានទទួលការសិក្សាដល់ឆ្នាំ២០១៦**
  -សិក្សានិងពិភាក្សាជាមួយឃុំចំនួនពីរ(ឃុំកំពង់ល្ពៅ និងឃុំតាគោក) និងកម្រងចំនួន២គឺកម្រងអូរជាំ អូរតាទៀក កំណត់ពីតំបន់និងសាលាដែលមានបញ្ហាកុមារពិការមិនបានចូលរៀន និង បានសិក្សាកំណត់ពី ប្រភេទកុមារពិការ និងតម្រូវការ របស់គេ ក្នុងឃុំចំនួន២ មានឃុំតាគោកនិង កំពង់ល្ពៅ ដែលមានភូមិចំនួន ១៨ភូមិ ក្នុងនោះចំនួនកុមារពិការ សរុប១១២នាក់ ស្រី៥៦នាក់ ជនពិការក្នុងភូមិ សរុប៣៧១នាក់ ស្រី៥៨ នាក់ និងបានកំណត់ស៊ីជម្រៅលើគោលដៅសាលាចំនួន១០សាលា ក្នុង២កម្រងគឺ កម្រងអូរតាទៀក និងកម្រងអូរជាំ(សាលាអូរតាទៀក អូរសំរិល សាលាភ្នំរ៉ៃ អូរននោង សាលាពាមតា សាលាកំពង់ល្ពៅ សាលាអូរជាំក្រោម សាលាអូរជាំភូមិកណ្តាលស្ទឹងតូចក្រោម)ក្នុងនោះសិស្សពិការ សរុប៩៦ស្រី៣៦នាក់ សម្រាប់ផ្តល់អន្តរាគមន៍និងរកសេវាជំនួយ និងដាក់បញ្ចូលក្នុងកម្មវិធីអប់រំបញ្ចូលគ្នា ជាមួយកុមារមិនពិការក្នុងសាលារៀនគោលដៅមានស្រាប់ និងបានបើកថ្នាក់មត្តេយ្យសិក្សាសហគមន៍ បន្ថែមចំនួន២ទៀត ។

-ធ្វើបច្ចុប្បន្នភាពគណៈកម្មការទ្រទ្រង់ជនពិការ ចំនួន១០ក្រុមស្មើរ១០ភូមិ ក្នុងឃុំ២ គឺៈ ឃុំតាគោក និង ឃុំកំពង់ល្ពៅ មាន ភូមិអូរតាទៀកភូមិភ្នំរៃភូមិអូរត្រែងភូមិវាលរលឹមភូមិអូរក្រូចភូមិស្វាយជ្រុំភូមិកំពង់ល្ពៅ ភូមិអូរដើមចេកភូមិស្ទឹងតូចក្រោមភូមិអូរជាំក្រោម ដែលមានសមាជិកសរុប៥០ស្រី៩នាក់ ដោយមានពិការ ភាពដាក់ជាសមាសភាព១នាក់ជនពិការក្នុងក្រុម។

-សហការសម្របសម្រួល ការធ្វើនិង ទទួលឯកសារផ្លូវការសម្រាប់កុមារពិការមានលិខិតផ្សេងៗ ក្នុងនោះមាន សិស្សពិការសរុប៨០នាក់ ស្រី៣៨នាក់បានទទួលសំបុត្របញ្ជាក់កំណើតនិងប័ណ្ណក្រីក្រ។

-បានជួសជុលនិងធ្វើជំរាលសម្រាប់កុមារពិការបានចូលរៀនងាយក្នុងថ្នាក់បាន៨សាលារៀន គឺៈសលាបឋម សិក្សាពាមតាអូរននោងភ្នំរៃអូរតាទៀកអូរសំរិលអូរជាំអូរជាំក្រោម និងស្ទឹងតូចក្រោម ដោយមានផងដែរ ជម្រាលផ្ទាប់ដល់បង្គន់សិស្ស។

- **អភិវឌ្ឍន៍បរិស្ថានសាលាមានភាពងាយស្រួលដល់កុមារពិការចេញចូល និង ការគ្រប់គ្រងសាលារៀន ងាយស្រួលដល់កុមារពិការ**

  -សហការជាមួយមន្ត្រីជំនាញអប់រំស្រុក បំប៉នគ្រូបង្រៀន និងបើកសិក្ខាសិលាស្តីពី **កម្មវិធីអប់រំបញ្ចូលគ្នា** និង ផលិតសម្ភារៈបង្រៀមបានក្នុង២កម្រងសលាល គ្រូបង្រៀនចូលរួមសរុបចំនួន៤៩ នាក់ ស្រី២៦នាក គ្រូពិការមានចំនួន ៣នាក់។

  -ផ្តល់ការឧបត្ថម្ភប្រាក់ខែគ្រូមត្តេយ្យសហគមន៍ (២សាលាគឺអូរសំរិល និងអូរតាទៀក) និង គ្រូជំនួយដល់ កុមារពិការក្នុងថ្នាក់ឬសាលារោន បាន៥សាលាគឺៈ សាលាកំពង់ល្ពៅសលាអូរជាំ សាលាអូរជាំក្រោម សាលាស្ទឹងតូក្រោមនិងសាលាពាមតា ដោយគ្រូបង្រៀននិងគ្រូជំនួយយកចិត្តទុកដាក់ និងបង្ហាត់កុមារពិការ ជាពិសេសជាមួយកុមារមិនពិការ ដើម្បីពួកគេមានភាពរីករាយរៀនសូត្រនិងយល់ពីគ្នា និងចេះសហការគ្នា និងជួយកាត់បន្ថយភាពរើសអើង។

  -បានគាំទ្រនូវដំណើរការថ្នាក់សាលារៀនបឋមសិក្សាសហគមន៍ចំនួន៧ថ្នាក់ មានសិស្សសរុប៦៧នាក់ ស្រី៣៤នាក់ និងឧបត្ថម្ភប្រាក់ខែគ្រូចំនួន៩នាក់ ក្នុង១ខែ$២០.០០ប្រចាំខែ ពេញ១ឆ្នាំសិក្សា២០១៤-១៥។

  -ប្រជុំផ្សព្វផ្សាយលើកកម្ពស់សិទ្ធិជនពិការ ពីសមត្ថភាពជនពិការ និងតម្រូវការរបស់ជនពិការ និងសហគមន៍ មេត្រីភាពចំនួន៨ភូមិ អ្នកចូលរួមសរុប ១៩៣នាក់ ស្រី១០២នាក់ជនពិការសរុប៦៧នាក់ ស្រី១៩នាក់ ដោយបញ្ជ្រាបពីការអភិវឌ្ឍន៍ដោយមានត្រូវបានគិតពីជនពិការចូលរួម និងលើកកម្ពស់គោលនយោបាយ និងផែនការសកម្មភាពសម្រាបជនពិការ និងការអប់រំបរិយាប័ណ្ណ (ការអប់រំបញ្ចូលគ្នា) ដោយសហគមន៍បាន យល់ដឹងនិងឃុំបានកំណត់អាទិភាពដោយបានបញ្ជ្រាបរាល់បញ្ហាពិការក្នុងរៀបវារៈក្នុងការជជែក និង ផែនការភូមិ និងឃុំ និងស្រុក។

- **បំប៉នសមត្ថភាពសហគមន៍ មាតាបិតា គាំទ្រជួយដល់កុមារពិការបានសម្របនិងត្រឹមត្រូវ និងចូលរួមយោបល់**
  -បានរៀបចំបើកសិក្ខាសិលាស្តីពី មាតាបិតាថែទាំកូនបានល្អ (ជាមួយមាតាបិតាមានកូនពិការ) ១លើក អ្នកចូលរួមសរុបចំនួន២០នាក់ស្រី៧នាក់ បានជម្រុញការយល់ដឹងដល់អាណាព្យាបាលមានទំនួលខុសត្រូវ និងសិទ្ធិកុមារពិការ និងការថែទាំកូនពិការដោយសមស្របជាជាងការទុកចោល និងមិនបានឲ្យចូលរៀន និង ពិភាក្សាពិគុណតម្លៃសិក្សារបស់កុមារពិការ និង ជំនាញជាមាតាបិតាល្អ។

  -បានចងក្រងក្រុមគណៈកម្មការទ្រទ្រង់ជនពិការបាន១០ក្រុម និងមាតាបិតាល្អបាន៩ក្រុម ដើម្បីជួយចលនាធនធាននិងចេះជួយខ្លួនឯង និងជួយគ្នាពេលមានបញ្ហាណាមួយ និង ចែករំលែកពីទស្សនៈ យល់ដឹងពីការមើលឃើញពីសមត្ថភាពរបស់កុមារពិការ ជាជាងឃើញតែពិការភាពរបស់គេ។

  -ការចុះត្រួតពិនិត្យនិងតាមដានតាមសាលារៀនមានកុមារពិការចូលរៀនៈ មានសាលាអូរសំរិល សាលាអូរតាទៀក សាលាកំពង់ល្ពៅ សាលាអូរជាំ សាលាពាមតា សាលាអូរជាំក្រោម និងសាលាស្ទឹងតូក្រោម និងបានជួបប្រាស្រ័យជាមួយគ្រូបង្រៀនជាមួយនាយកនិងពិនិត្យពីការបង្រៀននិងកិច្ចតែងការបង្រៀនបែបបរិយាប័ណ្ណ(អប់រំបញ្ចូលគ្នា) និងភាពរីកចំរើនរបស់កុមារពិការរៀនសូត្រ។

- ការចុះត្រួតពិនិត្យនិងតាមដានសកម្មភាពរៀន និងបង្រៀនរបស់លោកគ្រូ អ្នកគ្រូសាងសង់សាលា ធ្វើសួនបង្គន់អនាម័យ កន្លែងលាងដៃ កន្លែងដុតសំរាម តាមសាលាគោលដៅទាំង១១សាលារដ្ឋនិង ១១សាលាសហគមន៍ ពីមន្ត្រីជំនាញ បុគ្គលិកគម្រោង និងបុគ្គលិកស្ម័គ្រ។

## III- គម្រោងទី៣ ការសាងសង់សាលាបឋមសិក្សាសហគមន៍ចំការស្រូវ

រយៈពេលគម្រោង:		៣ខែ (ចាប់ពីខែកញ្ញា ដល់ធ្នូ ២០១៥)
គាំទ្រថវិកាដោយសប្បុរសជនពីប្រទេសអង់គ្លេស (ក្រុមហ៊ុន Veritas Digital Service LTD. UK)
អនុវត្តគម្រោងដោយ:	អង្គការខ្មែរដើម្បីការអប់រំ (KHEN)
បដិភាគ:			ពីសហគមន៍ចំការស្រូវនៃភូមព្រៃធំ និងនាយកកម្រងនិងសាលារៀន
តំបន់គោលដៅ:		សហគមន៍ចំការស្រូវ ភូមិព្រៃធំ ឃុំកំពង់ល្ពៅ ស្រុកសំឡូត ខេត្តបាត់ដំបង

### <u>លទ្ធផលសម្រេចបាន</u>

គម្រោងបានសាងសង់អាគារសាលារៀនបឋមសិក្សាពីឈើថ្មី មួយខ្នង មាន៣បន្ទប់រៀន (បណ្តោយ ២៤ម និង ទទឹង៦ម) និងបន្ទប់ទឹកស្រីប្រុស១ខ្នងមាន២បន្ទប់និងរៀបចំសួននិងសហគមន៍ចូលរួមបន្ថែមចាក់ផ្លូវចូលសលារៀន និងដាក់ឡូសម្រាប់សិស្សបានសាលាថ្មីនិងសមស្របសម្រាប់សិក្សា ដោយមានពីកំរិតទី១ដល់ទី៥ សរុបចំនួន ៥៨នាក់ ស្រី២៩នាក់ក្នុងសហគមន៍ចំការស្រូវ នៃភូមិព្រៃធំ ឃុំកពង់ល្ពៅ ស្រុកសំឡូត ។ ក្រោយពីសាលារៀន បានសង់រួច នាយកសាលាបានរាយការណ៍ថា កំនើនសិស្សបានកើនដល់៧២នាក់ នាចុងឆ្នាំ២០១៥ ។

## IV- ឈ្មោះគម្រោងទី ៤ កម្មវិធីសវនកម្មសង្គម

រយៈពេលគម្រោងសាកល្បង: ៣ខែ (ចាប់ពីខែកញ្ញា ដល់វិច្ឆិកា ២០១៥)
គាំទ្រថវិកាដោយ: អង្គការ NEP (កញ្ចប់ថវិកាខ្នាតតូច)
អនុវត្តគម្រោងដោយ: អង្គការខ្មែរដើម្បីការអប់រំ (KHEN)
តំបន់គោលដៅ: ២សាលារៀនគោលដៅ ឃុំកំពង់ល្ពៅ និងតាតោក ស្រុកសំឡូតខេត្តបាត់ដំបង

**លទ្ធផលសម្រេចបាន**

សវនកម្មសង្គមជាកម្មវិធីរៀបចំជាវេទិកាសាធារណៈជជែកស្មើភាពគ្នារវាងអ្នកទទួលបានសេវាពីរដ្ឋ និងអ្នកទទួលបានសេវាជាពិសេសកុមារ និងរៀបចំផែនការជាក់លាក់តាមកិច្ចសន្យាដែលបានឯកភាព និងលើកឡើងក្នុងពេលពិភាក្សាសវនកម្មសង្គម លើប្រធានបទដែលគម្រោងបានសហការរៀបចំវេទិកាស្តីពីៈ **បរិស្ថានសាលារៀនស្អាត និង គុណភាពការរៀន និងបង្រៀននៅកម្រិតបឋមសិក្សា** បានចំនួន២លើក អ្នកចូលរួមសរុប ១២២ ស្រី៧៩នាក់ ជនពិការ៩នាក់ ជនជាតិភាគតិច១ ស្រី១នាក់ដោយបានចូលរួមពីអ្នកផ្តល់សេវាមានឃុំ ការិយាល័យអប់រំ និងសាលារៀន ជាវាគ្មិនតំណាងរដ្ឋ និង ប្រជាពលរដ្ឋជាអ្នកមានតម្រូវការសម្រាប់ការសិក្សារបស់កុមារជាពិសេសតម្រូវការតាម**បទដ្ឋានអប្បបរិមាសាលាកុមារមេត្រី** ដែលក្រសួងអប់រំយុវជននិងកីឡា បានចាត់ទុកជាតម្រូវការសម្រាប់ ធានាបានថាកុមារគ្រប់រូបៗទទួលបានសិទ្ធិនិងការអប់រំមានមានគុណភាព ។សវនកម្មសង្គមនេះ បានជួយពង្រឹងដល់ប្រជាពលរដ្ឋ និងសហគមន៍អាចលើកឡើងដោយផ្ទាល់ជាមួយវាគ្មិនពីថ្នាក់ស្រុក-ឃុំនិងការិយាល័យអប់រំនិងគ្រូបង្រៀនជាអ្នកផ្តល់សេវានិងតំណាងមាតបិតាសិស្សជាអ្នកលើកឡើងតម្រូវការ ។ កម្មវិធីនេះ បានផ្តល់នូវភាពវិជ្ជមានក្នុងការនិយាយត្រង់និងផ្តល់ការសន្យានិងយោគយល់គ្នាជាជាងការដាក់បន្ទោសនិងតិទៀនគ្នា។

## V- សេចក្តីសន្និដ្ឋានរួម

កុមាររស់នៅតំបន់កំពុងជួបការលំបាក និងជនបទ ព្រៃភ្នំ ផងដែរកុមារពិការ និងងាយរងគ្រោះ មានឱកាសបានចូលរៀន ដូចកុមារដទៃទៀត ហើយទន្ទឹមនឹងនេះប្រជាពលរដ្ឋយល់ដឹងកាន់តែប្រសើរឡើងអំពីការគោរពសិទ្ធិកុមារ និងកិច្ចការពារកុមារទាំងអស់គ្នា តាមរយៈ ការចូលរួម និងទទួលបានសិទ្ធិ និងមានការគាំពារនិងផ្តល់សហការគ្រប់អ្នកពាក់ព័ន្ធទាំងអស់ និងអ្នកទទួលផលទាំងអស់។

ការខិតខំប្រឹងប្រែង និងការអនុវត្តគម្រោង របស់អង្គការខ្មែរដើម្បីការអប់រំ ដោយកិច្ចសហការល្អភាពជាដៃគូជាមួយការិយាល័យពាក់ព័ន្ធ និងមូលដ្ឋានឃុំស្រុកខេត្ត គឺឆ្លុះបញ្ចាំងអោយឃើញលទ្ធផលគួរអោយកត់សំគាល់និងផ្លែផ្កាល្អដល់កុមារនិងសហគមន៍របស់គេក្នុងតំបន់នៃ ស្រុកសំឡូត នៅក្នុងឆ្នាំ ២០១៥នេះ ។

អង្គការខ្មែរដើម្បីការអប់រំ និងក្រុមការងារពិតជានៅមាន ឆន្ទៈ និងពុះពារបន្តក្នុងបេសកកម្មរបស់ខ្លួន ទៅមុនទៀត ដើម្បី**ឧត្តមប្រយោជន៍កុមារ**កម្ពុជា ជាពិសេសកុមារក្នុងតំបន់ជួបប្រទះការលំបាក និងជនបទ ដោយធ្វើការក្នុងភាពជាដៃគូសហការផ្ទាល់ពីមន្ទីរ/ការិយាល័យជំនាញ អាជ្ញាធរនិងមូលដ្ឋានគ្រប់លំដាប់ និងដោយមានការគាំទ្រពីម្ចាស់មូលនីធិនានា នៅពេលខាងមុខបន្តទៀត។

ធ្វើនៅសំឡូត ថ្ងៃទី ០៥ ខែមករា ឆ្នាំ ២០១៦

**នាយកប្រតិបត្តិ**

**អង្គការខ្មែរដើម្បីការអប់រំ**